ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ សុក្រ ១៥ កើត ខែជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបពិភាក្សាការងារ
## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ជាមួយឯកឧត្តមវេជ្ជបណ្ឌិត សាអៀ ម៉ាអ៊ូ ព្យូកាឡា
## ប្រធានប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច នៃអង្គការសុខភាពពិភពលោក

នាព្រឹកថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០២៤, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន អនុញ្ញាតឱ្យឯកឧត្តមវេជ្ជបណ្ឌិត **សាអៀ ម៉ាអ៊ូ ព្យូកាឡា** (Saia Ma'u Piukala) ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារក្នុងឱកាសនៃដំណើរទស្សនកិច្ចជាលើកដំបូងនៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តមវេជ្ជបណ្ឌិត **សាអៀ ម៉ាអ៊ូ ព្យូកាឡា** និងសហការី ក្នុងឱកាសមកបំពេញបេសកកម្មការងារនៅប្រទេសកម្ពុជាជាលើកដំបូង បន្ទាប់ពី **ឯកឧត្តមវេជ្ជបណ្ឌិត** ត្រូវបានជ្រើសតាំងជាប្រធានប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច នៃអង្គការសុខភាពពិភពលោក កាលពីខែ កុម្ភៈ ឆ្នាំ ២០២៤ កន្លងមក ។ ក្នុងកិច្ចជំនួស, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានគូសរំលេច អំពី កិច្ចសហប្រតិបត្តិការដ៏ល្អ រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសុខភាពពិភពលោក ក្នុងរយៈកាលជាច្រើន ទស្សវត្សន៍កន្លងមក និងបានវាយតម្លៃខ្ពស់ ចំពោះអង្គការសុខភាពពិភពលោកក្នុងការចូលរួមចំណែកគាំទ្រ ដល់ការអភិវឌ្ឍវិស័យសុខាភិបាលកម្ពុជា រហូតរៀងមក ដែលរួមមានទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ និងជាពិសេសក្នុងកាលៈទេសៈដ៏លំបាក ពីការរាតត្បាតនៃជំងឺកូវីដ-១៩ ។

ឯកឧត្តមវេជ្ជបណ្ឌិត **សាអៀ ម៉ាអ៊ូ ព្យូកាឡា** បានសម្តែងនូវការអរគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក្នុងដំណើរបេសកកម្មការងាររបស់ឯកឧត្តម ព្រមទាំងបានកោតសរសើរ និងវាយតម្លៃខ្ពស់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍប្រទេស ជាមួយនឹងការដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងការវិនិយោគជាបន្តបន្ទាប់ រហូតមានការរីកចំរើនសង្គម-សេដ្ឋកិច្ចគួរឱ្យកត់សំគាល់ ។ ទន្ទឹមនេះ, ឯកឧត្តមវេជ្ជបណ្ឌិតក៏បានថ្លែងកោតសរសើរកម្ពុជាលើភាពជោគជ័យក្នុងការទប់ស្កាត់ និងឆ្លើយតបនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងការកែទម្រង់ប្រព័ន្ធសុខាភិបាលកម្ពុជាឱ្យកាន់តែមានភាពរីកចំរើនប្រកបដោយភាពធន់ និងរឹងមាំ ដែលអាចត្រៀមខ្លួន

ឆ្លើយតបទៅនឹងបញ្ហាប្រឈម និងជំងឺរាតត្បាតជាយថាហេតុនានាដែលអាចកើតមានឡើងនាពេលអនាគត។ ឆ្លៀតក្នុងឱកាសនេះ, **ឯកឧត្តមវេជ្ជបណ្ឌិត** ក៏បានថ្លែងអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ "**ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅ កម្ពុជាឆ្នាំ ២០២៤-២០៣៥**" ព្រមទាំងបានបញ្ជាក់អំពីការគាំទ្រយ៉ាងមុតមាំរបស់អង្គការសុខភាពពិភពលោកតាមរយៈកិច្ចសហការជាមួយក្រសួងសុខាភិបាលកម្ពុជា ដើម្បីជំរុញការអនុវត្តផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់នេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

ជាមួយនឹងការថ្លែងអំណរគុណជាថ្មីម្តងទៀត, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងអំពី ភាពជោគជ័យ និងសមិទ្ធិផលរបស់កម្ពុជានាពេលបច្ចុប្បន្ន គឺជាផ្លែផ្កានៃការសម្រេចបាននូវសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** ។ ជាមួយគ្នានេះ, ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ដែលមាន**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី, "**មនុស្ស**" គឺជាអាទិភាពគន្លឹះទី ១ នៃ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**" ហើយ "**ការផ្តល់ការថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា**", ការបន្តលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស និងសុខុមាលភាពរបស់ពលរដ្ឋ តាមរយៈការបន្តជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គមឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាព គឺជាកម្មវិធីគោលនយោបាយអាទិភាពទី ១ សម្រាប់ការអភិវឌ្ឍប្រទេស ក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត ។

ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានស្នើសុំឱ្យអង្គការសុខភាពពិភពលោកបន្តគាំទ្រកម្ពុជាទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចជាសកល របស់សន្និបាតអង្គការសុខភាពពិភពលោកស្តីពីបញ្ហាសុខភាព និងបម្រែបម្រួលអាកាសធាតុ ក៏ដូចជាកម្មវិធីការងារទូទៅទីដប់បួនថ្មីរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០២៥-២០២៨ ដែលមានគោលបំណងលើកកម្ពស់ការការពារសុខភាព និងសុខុមាលភាពសម្រាប់មនុស្សទាំងអស់គ្នានៅគ្រប់ទីកន្លែង ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយកដ្ឋមន្ត្រី** បានជូនពរ **ឯកឧត្តមវេជ្ជបណ្ឌិត** ព្រមទាំងសហការីឱ្យទទួលបានជោគជ័យក្នុងដំណើរបេសកកម្មរបស់ខ្លួន និងជឿជាក់យ៉ាងមុតមាំថាបេសកកម្មការងារនេះ នឹងរួមចំណែកដល់ការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការសុខភាពពិភពលោកឱ្យកាន់តែរឹងមាំបន្ថែមទៀត ។